**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៣៤៤ សជណ.ណក

ថ្ងៃ សុក្រ ១២កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**សូមគោរពជូន**
**សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**
**នៅថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ ៖** ករណីសំណើសុំគោលការណ៍អំពីការបន្តនិរន្តរភាពនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងស្ថានភាពដែលដៃគូអភិវឌ្ឍន៍មួយចំនួនបានបញ្ចប់ការគាំទ្ររបស់ខ្លួន។

**យោង ៖** - លិខិតលេខ ១០៨ លស/គ.ជ.អ.ប ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ចំណារដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីមានកិត្តិយសសូមគោរពជម្រាបជូន សម្ដេចក្រឡាហោម មេត្តាជ្រាបថា ចំពោះករណីសំណើសុំគោលការណ៍អំពីការបន្តនិរន្តរភាពនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងស្ថានភាពដែលដៃគូអភិវឌ្ឍន៍មួយចំនួនបានបញ្ចប់ការគាំទ្ររបស់ខ្លួន រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍ ដូចខាងក្រោម៖

១-ផ្ដល់ថវិកាដល់ គ.ជ.អ.ប. ចំនួន ២លានដុល្លារ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៨ តទៅ ដើម្បីប្រើប្រាស់ក្នុងការដឹកនាំ សម្របសម្រួល និងអនុវត្តនូវសកម្មភាពស្នូល និងការចំណាយលើកិច្ចប្រតិបត្តិការនានារបស់ គ.ជ.អ.ប.។

២- អនុញ្ញាតឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទាំងអស់ (ដែលធ្លាប់បានទទួលថវិកាគាំទ្រពី "ថវិកាកញ្ចប់រួម" របស់ គ.ជ.អ.ប. ដែលធ្លាប់បានទទួលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទាំង៣ខាងលើ) ប្រើប្រាស់នូវថវិកាប្រចាំឆ្នាំរបស់ស្ថាប័នសាមីនីមួយៗ ដោយធ្វើអាទិភាពឡើងវិញនូវគម្រោងចំណាយប្រចាំឆ្នាំ២០១៨ ដែលបានអនុម័តរួចហើយ ដើម្បីដាក់បញ្ចូលនូវការចំណាយសម្រាប់អនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ចាប់ពីឆ្នាំ២០១៨ តទៅ ដោយផ្អែកលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែល សម្របសម្រួល រៀបចំ និងអនុម័តដោយ គ.ជ.អ.ប.។

៣- ក្នុងករណីដែលដៃគូអភិវឌ្ឍន៍ណាមួយសម្រេចចិត្តបន្តការគាំទ្ររបស់ខ្លួន អនុញ្ញាតឱ្យ គ.ជ.អ.ប.ប្រើប្រាស់ហិរញ្ញប្បទានទាំងនោះដោយផ្តោតលើការវិនិយោគទៅលើគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងការគាំទ្រដល់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្របច្ចេកទេសតាមការចាំបាច់នានា។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេចក្រឡាហោម មេត្តាជ្រាប និង ចាត់ចែងអនុវត្ត។

**ឧ.រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ស៊ូ គិរិន្ទ**

**ចម្លងជូន ៖**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ